ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាជំនុំរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ: ១៣២

ចុះថ្ងៃទី ១៨.០៥.៩៨

សាលដីកា

លេខ: ១៥៨

ចុះថ្ងៃទី ២៣.០៧.៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចខាងក្រោម:-

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២ - លោក ខ៉េន ស៊ិន ជាចៅក្រម

៣ - លោក ទៀល មួន ជាចៅក្រម

៤ - លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៥ - លោក ស៊ិន ទីម ជាចៅក្រម

ក្រឡាបញ្ជី

លោក ទេវ ដាណា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា លេខ ១៦៦ ចុះថ្ងៃទី ២៨.០៤.៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៧៨ ចុះថ្ងៃទី ០១.០៨.៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សុខ លាង អាយុ ៣៩ ឆ្នាំ ជាតិ ខ្មែរ មុខរបរ លក់គ្រឿងដែក ទីលំនៅផ្ទះលេខ ២៦១៦E ផ្លូវព្រះមុនីវង្ស ខ័ណ្ឌដូនពេញ ។ ឪពុកឈ្មោះ សុខ ពេង "ស" ម្តាយឈ្មោះ អ៊ឹង ក្លិប "រ" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ សៀង យ័ន្ត អាយុ ៥៨ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់គុយទាវ ទីលំនៅផ្ទះលេខ ២២១៤ អឺ០ , អឺ១ , អឺ២ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ។ ឪពុកឈ្មោះ ? ម្តាយឈ្មោះ ? ។

កម្មវត្ថុបណ្តឹង: ប្តឹងទាមទារសំណងការខូចខាតផ្ទះ

បានឃើញបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី ២៩.០៤.៩៨ របស់ឈ្មោះ សុខ លាង ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងស្រុង ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី ១៨.០៥.៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៤.១២.៩៦ របស់ដើមចោទឈ្មោះ សៀង យ័ន្ត ប្តឹងសុំអោយឈ្មោះ សុខ លាង សងសំណងការខូចខាតផ្ទះរបស់ខ្លួនបណ្តាលមកពីការបុកគ្រឹះចំនួន ២៥០០០ ដុល្លារអាមេរិក ទារថ្លៃបាត់បង់អាជីវកម្មចំនួន ២៩០០០ ដុល្លារអាមេរិក និង ជំងឺចិត្តចំនួន ៧៥០០ ដុល្លារអាមេរិក ដោយហេតុថា ផ្ទះរបស់ខ្លួនទើបតែសាងសង់ថ្មីរួចរាល់រយៈពេល ៨ ខែប៉ុណ្ណោះ ហើយនៅថ្ងៃទី ...

០២.១២.៨៤ ឈ្មោះ សុខ លាង បានមកសាងសង់ឃ្លាំងថ្មីនៅជាប់ផ្ទះរបស់ខ្លួន នៅពេលចុកគ្រឹះសាងសង់នោះ បានធ្វើអោយប្រេះស្រាំខូចខាតស្ទើរតែទាំងស្រុងដល់ផ្ទះរបស់ខ្លួនតាំងពីជាន់ក្រោមរហូតដល់ជាន់លើ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៩ "ឃ" ចុះថ្ងៃទី ២៧.០៣.៨៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:-

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៨.០២.៨៥ និង ពាក្យបណ្តឹងចុះថ្ងៃទី ០៤.១២.៨៦ របស់ សៀង យ័ន្ត មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធពាក្យបណ្តឹងចុះថ្ងៃទី ០៩.០៣.៨៥ របស់ចុងចម្លើយឈ្មោះសុខ លាង. ទុកជាអសារបង់ ។

៣- បង្គាប់អោយឈ្មោះ សុខ លាង សងសំណងការខូចខាតទៅឈ្មោះ ម៉េង គឹមឃួ ដែលជាតំណាងដើមចោទ ឈ្មោះ សៀង យ័ន្ត នូវចំនួនទឹកប្រាក់ ៨៧០០ដុល្លា " ប្រាំបីពាន់ប្រាំពីររយដុល្លាអាមេរិក " ថ្លៃបង់ខាតលើអាជីវកម្មចំនួន ១០០០ដុល្លា " មួយពាន់ដុល្លាអាមេរិក " និង ជំងឺចិត្តចំនួន ១០០០ដុល្លាអាមេរិក " មួយពាន់ដុល្លាអាមេរិក " គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៤- បង្គាប់អោយឈ្មោះ សុខ លាង បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១៨០០ រៀល រង្វាន់ក្រឡាបញ្ជីការពិបប្រាក់ ២០០ រៀល រង្វាន់អ្នកប្រឹក្សាដីកាកោះ ៥០០០ រៀល សរុប ៧០០០ រៀល ដែលដើមចោទបានបង់ទុកជាប្រេប ចាប់ពីសាលក្រមចូលស្ថាពរ ។ កាលបើប្តឹងបណ្តឹងឧទ្ធរណ៍ ត្រូវបង្គាប់អោយចុងចម្លើយបង់ពន្ធសមាមាត្រមួយភាគរយនៃប្រាក់ ៨៧០០ដុល្លាអាមេរិក ស្មើនឹង ៨៧ដុល្លាអាមេរិក ក្នុងនោះត្រូវដាក់ចូលថវិការដ្ឋ ៨០ ភាគរយនៃប្រាក់ ៨៧ ដុល្លាអាមេរិក ស្មើនឹង ៦៩,៦០ ដុល្លា និង បានរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ចំនួន ២០ភាគរយនៃប្រាក់ ៨៧ដុល្លាអាមេរិក ស្មើនឹង ១៧,៤០ដុល្លាអាមេរិក ។ ពន្ធសមាមាត្រនេះត្រូវអោយដើមចោទបង់ជាមុន ក្រោយពីសាលក្រមចូលជាស្ថាពរ និង បង្គាប់អោយចុងចម្លើយ សងទៅដើមចោទវិញជាក្រោយ ។

៥- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេលពីរខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញសេចក្តីសុំប្តឹងតវ៉ាលេខ ១៣ ចុះថ្ងៃទី ២៨.០៤.៨៧ របស់ឈ្មោះ សុខ លាង ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់តុលាការក្រុងភ្នំពេញទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៦៦ ចុះថ្ងៃទី ២៨.០៤.៨៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:-

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨.០៤.៨៧ របស់ឈ្មោះ សុខ លាង ទុកជាត្រឹមត្រូវតាមទំរង់ ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៩ "ឃ" ចុះថ្ងៃទី ២៧.០៣.៨៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០ រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ២៥៥០ រៀល រង្វាន់ក្រឡាបញ្ជីការពិបប្រាក់ ៤៥០ រៀល រង្វាន់អ្នកប្រឹក្សាដីកាកោះ និង អាជ្ញាធរតុលាការ ១០០០០ រៀល សរុប ១៣០០០ រៀល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី ២៩.០៤.៩៨ របស់ឈ្មោះ សុខ លាង ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា

សាលដីការដ្ឋប្បវេណីលេខ ១៦៦ ចុះថ្ងៃទី ២៨.០៤.៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះផ្ទុយពីគតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ លាង នៅពេលជំនុំជំរះថា ការកាត់ក្តីរបស់សាលាឧទ្ធរណ៍ មិនបានរកយុត្តិធម៌អោយខ្លួនទេ ហើយសាលាឧទ្ធរណ៍កាត់ក្តីមិនបានពិនិត្យមើលបដិកោសរបស់ខ្ញុំទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ហេង គឹមឈួ នៅពេលជំនុំជំរះថា កាលដើមឡើយតុលាការក្រុងបានអោយទៅខាងមន្ទីររៀបចំក្រុងនិងសំណង់វាយតំលៃ ប៉ុន្តែខាងមន្ទីររៀបចំក្រុងថា មិនមែនជាសមត្ថកិច្ចរបស់ខ្លួនទេ ក៏អោយទៅខាងលោក កុយ គឹមផន ធ្វើវិញ ។ បាទខ្លួនសុំអោយតុលាការកំពូលជួយរកយុត្តិធម៌អោយខ្លួនផង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ ដែលសន្និដ្ឋានក្នុងសារណា ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៨ របស់លោក សុខ លាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការក្រុងភ្នំពេញដែរ ដែលសំរេចសេចក្តីអោយលោក សុខ លាង សងការខូចខាតទៅលោក សៀង យ័ន្ត ដោយផ្អែកទៅលើការវាយតំលៃរបស់ក្រុមហ៊ុនសំណង់ឯកជនមុំសុខ និង របាយការណ៍លេខ ០៤៨ អធក ចុះថ្ងៃទី ១៣.១០.៩៥ របស់លោកកុយ គឹមផន នោះជាការពុំត្រឹមត្រូវទេពីព្រោះថាៈ -

ក- ការវាយតំលៃរបស់ក្រុមហ៊ុន មុំ សុខ ជាក្រុមហ៊ុនឯកជន ហើយពុំមែនធ្វើការវាយតំលៃតាមការចាត់តាំងរបស់តុលាការឡើយ ។

ខ- របាយការណ៍លេខ ០៤៨អធកចុះថ្ងៃទី ១៣.១០.៩៥ របស់លោក កុយ គឹមផន ត្រូវបានឯកឧត្តមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូនសុំដកយកទៅវិញតាមលិខិតលេខ ២៩៣៧សក.ខ ចុះថ្ងៃទី ០៣.១១.៩៥ រួចហើយ ហើយតុលាការក្រុងភ្នំពេញក៏បានយល់ព្រមអោយដកចេញវិញហើយដែរ ដូច្នេះតុលាការពុំអាចយករបាយការណ៍នេះ មកធ្វើជាមូលដ្ឋាន ដើម្បីសំរេចសេចក្តីបានឡើយ ។

- យល់ឃើញថា របាយការណ៍វាយតំលៃចុះថ្ងៃទី ១៤.០៨.៩៥ របស់ក្រុមបច្ចេកទេសនៃនាយកដ្ឋាន

នគរូបនីយកម្ម និង សំណង់ផ្ទាននៃក្រសួងសាធារណការ និងដឹកជញ្ជូន បានបញ្ជាក់អំពីមូលហេតុនៃការប្រេះស្រាំផ្ទះលោក សៀង យ័ន្ត ដូចហើយគឺការប្រេះស្រាំនេះពុំមែនបណ្តាលមកពីមូលហេតុនៃការបុកគ្រឹះផ្ទះចុងបន្ថែមតែម្យ៉ាងទេ គឺបណ្តាលមកពីសំណង់ខ្វះបច្ចេកទេសនៃផ្ទះរបស់លោក សៀង យ័ន្តផង ដែលលោកត្រូវទទួលខុសត្រូវតាមមាត្រា ១៣២ នៃក្រឹត្យច្បាប់លេខ ៣៨ក្រប ។ របាយការណ៍នេះក៏ពុំបានបែងចែកនូវចំណែកនៃការទទួលខុសត្រូវរបស់ភាគីនិមួយៗទេ ។

- យល់ឃើញថា ដោយហេតុថា របាយការណ៍វាយតម្លៃរបស់ក្រុមហ៊ុនសំណង់ ម៉ុស្កូ របាយការណ៍របស់លោក គុយ គឹមផន និង របាយការណ៍របស់ក្រុមបច្ចេកទេសនគរូបនីយកម្ម និង សំណង់ផ្ទានពុំមានលទ្ធផលដូចគ្នាទេ ទើបសាលាឧទ្ធរណ៍បានចាត់របៀបអោយធ្វើបដិកោសល្យវិច្ឆ័យឡើងវិញ ។ ប៉ុន្តែសាលាឧទ្ធរណ៍បែរជាពុំយកលទ្ធផលនៃបដិកោសល្យវិច្ឆ័យនេះមកពិចារណាឡើយ ដោយអាងហេតុថា ការវាយតម្លៃលើការខូចខាតមានលក្ខណៈខុសពេក ហើយថាសមាសភាពដែលធ្វើបដិកោសល្យវិច្ឆ័យនេះជាសមាសភាពចាស់ ដែលបានធ្វើកោសល្យវិច្ឆ័យពីមុនរួចហើយ ។ ការយល់ឃើញបែបនេះរបស់សាលាឧទ្ធរណ៍ជាការភាន់ច្រឡំពីព្រោះថា វិស្វករ ៤នាក់ដែលបានចុះពិនិត្យ វាយតម្លៃនិងធ្វើរបាយការណ៍សុទ្ធតែជាវិស្វករជំនាញនិងមានសមត្ថកិច្ចដែលពុំបានចូលរួមក្នុងការធ្វើរបាយការណ៍លើកមុនទេ ឯលោក គ្រឹម ប៉េងហុង និង លោក ប៉ុក កុសល គ្រាន់តែជាអ្នកចូលរួមក្នុងនាមជាអាជ្ញាធរដែនដីប៉ុណ្ណោះ ។ ម្យ៉ាងទៀតពិនិត្យតាមរបាយការណ៍បដិកោសល្យវិច្ឆ័យឃើញថា របាយការណ៍នេះធ្វើឡើងបានហ្មត់ចត់ល្អិតល្អន់ និង បែងចែកការទទួលខុសរបស់ភាគីនិមួយៗបានច្បាស់លាស់ តាមកំហុសនៃសំណង់របស់ខ្លួន ដែលតុលាការយកជាការបាន ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមសំរេចអោយលោក សុខ លាង សងការខូចខាតការធ្វើអាជីវកម្មទៅដើមចោទ ដោយពុំបានបញ្ជាក់អំពីមូលហេតុច្បាស់លាស់នោះ ជាការខ្វះសំអាងហេតុ ។

7 - យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៦៦ ចុះថ្ងៃទី ២៨.០៤.៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី ចំពោះមុខគូក្ដី

១ - ទទួលបណ្ដឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៨ របស់លោក សុខ លាង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៦៦ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងស្រុង ។

៣ - បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩០០០រៀល ដែលលោក សុខ លាង បានបង់រួចហើយគឺ:-

- ពន្ធចុះបញ្ជីក្ដី និង ពន្ធធ្លឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីការនិងប្រាក់,

- ចំណាយលើកិច្ចប្រឹងដីកាកោះចំនួន ១៥០០០រៀល សរុប ១៩០០០រៀល ហើយត្រូវអោយលោក សៀង យ័ន្ត សងប្រាក់ចំនួន ១៩០០០រៀលនេះទៅលោក សុខ លាង វិញ ។

ល។

៥ - សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៨